# ទឹកចិត្ត

(បទពាក្យ៨)

វារីហូរទៅសំដៅទីទាប
ស្ទឹងបឹងទំនាបដងអូរទន្លេ
សមុទ្រធំជ្រៅទឹកនៅល្ហាចល្ហេ
មិនដែលមានទេហូរឡើងទីទួល។
ទឹកចិត្តនៃមនុស្សមិនខុសគ្នាឡើយ
បើសិនកន្តើយអោយទៅដោយស្រួល
បណ្តោយតាមចង់ចំណង់ខ្នាញ់ខ្នួល
ច្បាស់គិតជ្រើមជ្រួលរកទីថយថោក។
ទង្វើគ្រប់យ៉ាងអាងតាមចិន្តា
ធ្វើគ្មានវិចារណ៍តាមចិត្តល្ហែកល្ហោក
កាលធ្វើទៅហើយច្រើនជួបសោយសោក
ព្រោះចិត្តវាបោកអោយគួរមុនគិត។
ជនគ្រប់កាយអង្គចង់ណាស់សប្បាយ
សុខសាន្តប្រាណកាយទោះបីឆ្ងាយជិត
ចង់មានចង់បានថ្កើងថ្កានពេកពិត
ចង់អោយជីវិតផុតជ្រោះទុក្ខា។
ឯក្តីសប្បាយមានច្រើនរសជាតិ
សប្បាយក្រៅស្មៀតខុសក្បួនតម្រា
បណ្តោយរូបកាយធ្លោយតាមចិន្តា
នឹងជួបហីនាវិនាសមិនខាន។
សប្បាយមិនខ្សត់កំណត់ព្រំដែន
មានបែបមានផែនចេះស្គាល់ប្រមាណ
ទីណាគួរទៅណាត្រូវចៀសប្រាណ
ទង្វើប៉ុន្មានគិតអោយល្អិតល្អន់។
រំពឹងរកផលដែលផ្តល់តាមក្រោយ
មានសុខបានសោយ ឬទោសអាសន្ន
ថ្លៃថ្នូរថ្កុំថ្កើង ឬថោកអាប់អន់
មិនត្រូវទាន់ហន់ធ្វើតក់ក្រហល់។
លើកចិត្តអោយខ្ពស់ទោះកាលណាៗ
កុំតាមចិន្តាហ៊ឺហាជ្រួលច្រល់
ចិត្តនេះដូចទឹកតែងហូរទៅដល់
ទីទាបសោតសល់មិនដែលឡើងទួល។
គួរខំអប់រំបន្ទំអោយល្អ
ទើបបានបវរផុតខ្មៅខ្នាញ់ខ្នួល
ច្រានកាន់ទីខ្ពស់ឆ្ងាយក្តីក្តៅក្តួល
ទើបអាចទទួលបានភាពថ្លៃថ្នូរ។✍

*(២៦ តុលា ២០០២)*

*ភិក្ខុ ស្វាត សាលឿម*